**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ហេតុផលដែលជ្រើសរើសយកតំបន់ប៉ែកព្រៀសានធ្វើជាប៉ូលសេដ្ឋកិច្ចទី៤របស់កម្ពុជា
- សារៈសំខាន់នៃសេចក្តីព្រាងច្បាប់ស្តីពី «ការការពាររុក្ខជាតិ និងភូតគាមអនាម័យ»
- កម្ពុជាបានចំណូលពីការនាំចេញស្រូវ-អង្ករជាង៩៦លានដុល្លារត្រឹមពេល១ខែដំបូងនៃឆ្នាំ២០២២
- GDCE ដាក់បង្ហាញអត្រាពន្ធគយឆ្នាំ២០២២ នៅលើកម្មវិធីទូរស័ព្ទ
- ពលរដ្ឋត្អូញត្អែរពីតម្លៃសាំងកាន់តែឡើងថ្លៃ ខណៈមន្ត្រីថាមិនអាចគ្រប់គ្រងបាន
- ការលក់រថយន្តថ្មីក្នុងតំបន់អាស៊ានកំពុងកើនឡើងខ្ពស់ជាលើកដំបូង ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ
- ធនាគារកណ្តាលថៃ នឹងអាចបន្តរក្សាអត្រាការប្រាក់ នៅអត្រា ០,៥% នៅឆ្នាំ២០២២នេះ
- ពាណិជ្ជកម្មអន្តរជាតិឡាវ មានអតិរេកសរុប ១ប៊ីលានដុល្លារ ក្នុងឆ្នាំ២០២១
- ជប៉ុនត្រូវការពលករបរទេស៦លាននាក់នៅឆ្នាំ២០៤០
- ទីផ្សារការងារនៅអាមេរិកកើនឡើង ខៈណៈដែលអូមីក្រុងថមថយនាំឱ្យសេដ្ឋកិច្ចមានភាពរឹងមាំជាងមុន
- កិច្ចចរចាររវាងសហរដ្ឋអាមេរិក និងអ៊ីរ៉ង់លើកិច្ចព្រមព្រៀងនុយក្លេអ៊ែរ ទំនងជាអាចដកទណ្ឌកម្មលើការលក់ប្រេងនៅអ៊ីរ៉ង់ និងអាចបង្កើនការផ្គត់ផ្គង់ប្រេងនៅលើពិភពលោក
- ចិនក្លាយជាប្រទេសនាំចូលអាហារពីជប៉ុនធំបំផុតជាលើកដំបូងក្នុង**តម្លៃជិត២ពាន់លានដុល្លា**


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៣ ខែកុម្ភៈ ឆ្នាំ២០២២ លេខ ៖ ១០៦

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ហេតុផលដែលជ្រើសរើសយកតំបន់ប៉ែកឦសានធ្វើជាប៉ូលសេដ្ឋកិច្ចទី៤របស់កម្ពុជា



*ដោយខេមបូណ្ឌមីស(ផ្លូវជាតិលេខ៧ ចំណុចរង្វង់មូលខ្លាស្ទុះ ក្រុងក្រចេះ)*

កម្ពុជា មានប៉ូលសេដ្ឋកិច្ចចំនួន៣ បានចេញជារូបរាងមានដូចជា រាជធានីភ្នំពេញជាប៉ូលសេដ្ឋកិច្ចទី១,ខេត្តព្រះសីហនុ ជាប៉ូលសេដ្ឋកិច្ចទី២ និងខេត្តសៀមរាបត្រូវបានកំណត់ជាប៉ូលសេដ្ឋកិច្ចទី៣។ រាជរដ្ឋាភិបាលកម្ពុជា មានចក្ខុវិស័យកំណត់យកតំបន់ប៉ែកឦសានបង្កើតជាប៉ូលសេដ្ឋកិច្ចទី៤ របស់កម្ពុជា ក៏ព្រោះតែបានសម្លឹងឃើញពីសក្តានុពលខ្ពស់នៃវិស័យកសិ-ឧស្សាហកម្ម និងធនធានរ៉ែ ក្នុងខេត្តមួយចំនួន នៅប៉ែកឦសាននេះដូចជា ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ជាដើម។

ខេត្តក្រចេះមានសក្តានុពលផ្នែកកសិ-ឧស្សាហកម្ម ហើយខេត្តមណ្ឌលគិរី កំពុងមានសក្តានុពលផ្នែកធនធានរ៉ែ។ កម្ពុជា មិនទាន់មានការស្រាវជ្រាវអស់នៅឡើយ ដូចជា រ៉ែបុកស៊ីត រ៉ែត្បូង និងមានកន្លែងផលិតមាស ដទៃទៀត ដែលមិនទាន់បានប្រើប្រាស់។

ជុំវិញការផលិតមាស ត្រូវបានប្រមុខរាជរដ្ឋាភិបាលកម្ពុជា គូសបញ្ជាក់ថា ក្នុងរយៈពេល ៧ខែកន្លងមក កម្ពុជាផលិតបានមាសជាង ១,៧ពាន់គីឡូក្រាម ដែលជាមធ្យម យើងអាចផលិតមាស បានប្រមាណ ៨០គីឡូទៅ១០០គីឡូក្នុងមួយសប្តាហ៍។

ក្រសួងរ៉ែ និងថាមពល បានផ្តល់អាជ្ញាបណ្ណរុករករ៉ែលោហៈចំនួន២៦ អាជ្ញាបណ្ណដល់ក្រុមហ៊ុនចំនួន១៦ ដែលមកពីប្រទេសចិន អូស្ត្រាលី កាណាដា និងកម្ពុជា បានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម។ ក្នុងនោះមានក្រុមហ៊ុនមួយចំនួនកំពុងស្ថិតក្នុងដំណាក់កាលវាយតម្លៃសក្តានុពលធនធានរ៉ែ និងមួយចំនួនទៀតកំពុងរៀបចំរបាយការណ៍សិក្សាលទ្ធភាពនៃជម្រកធនធានរ៉ែ។ ហើយនៅឆ្នាំ២០២២ នេះក៏មានក្រុមហ៊ុនរុករករ៉ែមាសចំនួន៤ទៀតបានចាប់ផ្តើមធ្វើអាជីវកម្មចម្រាញ់រ៉ែមាសជាផ្លូវការរបស់ខ្លួននៅកម្ពុជា៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៨ខែកុម្ភៈ ឆ្នាំ២០២២។*

## តើគម្រោងតភ្ជាប់ផ្លូវទឹកពីទន្លេបាសាក់ទៅសមុទ្រកែបនឹងផ្តល់ផលប្រយោជន៍អ្វីខ្លះសម្រាប់កម្ពុជា?



ថ្មីៗនេះ រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន បានបង្ហាញពីគម្រោងរៀបចំឱ្យមានការតភ្ជាប់ការដឹកជញ្ជូនតាមផ្លូវទឹកពីទន្លេបាសាក់ ឆ្ពោះទៅកាន់សមុទ្រខេត្តកែបដើម្បីជំរុញការដឹកជញ្ជូនទំនិញតាមផ្លូវទឹក។ គម្រោងនេះពិតជានឹងចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យដឹកញ្ជូននៅកម្ពុជា ជំរុញការដឹកជញ្ជូនទំនិញតាមផ្លូវទឹក កាត់បន្ថយថ្លៃដឹកជញ្ជូនទំនិញ និង

កាន់តែបង្កើនឱកាសឱ្យកម្ពុជា អាចនាំទំនិញចេញ-ចូល កាន់តែងាយស្រួលទៅកាន់ទីផ្សារអន្តរជាតិ។

ប្រធានសមាគមភស្តុភារកម្មកម្ពុជា បានបង្ហាញការគាំទ្រយ៉ាងខ្លាំងចំពោះគម្រោងតភ្ជាប់ផ្លូវទឹកនេះដោយលោកបានអះអាងថា ការដឹកជញ្ជូនទំនិញតាមផ្លូវទឹកមានភាពងាយស្រួល និងចំណាយតិចជាងការដឹកជញ្ជូនតាមផ្លូវគោក និងផ្លូវអាកាស។ បច្ចុប្បន្ន នៅកម្ពុជាមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក នៅមានកម្រិតនៅឡើយ ដូច្នេះ គម្រោងនេះនឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងវិស័យដឹកជញ្ជូន។

រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន បានគូសបញ្ជាក់ថា ការតភ្ជាប់ផ្លូវទឹកពីទន្លេបាសាក់ទៅសមុទ្រកែប នឹងផ្តល់ផលចំណេញផ្នែកសេដ្ឋកិច្ចច្រើនសម្រាប់កម្ពុជា ព្រោះជាការតភ្ជាប់បណ្តាញទឹក ដើម្បីដឹកទំនិញទៅកាន់ទីផ្សារអន្តរជាតិ។ ក៏ប៉ុន្តែមិនទាន់អាចបញ្ជាក់នៅឡើយថា គម្រោងនេះ នឹងចាប់ផ្តើមសាងសង់នៅពេលណា ព្រោះគម្រោងនេះ ស្ថិតនៅក្នុងដំណាក់កាលសិក្សានៅឡើយ ហើយក៏មិនទាន់ដឹងថា ការសិក្សានឹងត្រូវបញ្ចប់ពេលណា និងត្រូវចំណាយទុនប៉ុន្មាននោះដែរ៕ *ដោយ ម៉ែន ខែមវៈ*

*ប្រភព៖ខេមបូឌាមីស ចេញផ្សាយថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២។*

## សារៈសំខាន់នៃសេចក្តីព្រាងច្បាប់ស្តីពី «ការការពាររុក្ខជាតិ និងភូតគាមអនាម័យ»



*ដោយ ខេមបូឌាមីស*

សេចក្តីព្រាងច្បាប់ស្តីពី«ការការពាររុក្ខជាតិ និងភូតគាមអនាម័យ» ត្រូវបានអនុម័តទាំងស្រុងរួចហើយ នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី៤ ខែកុម្ភៈឆ្នាំ២០២២នេះ។ ខ្លឹមសារនៅក្នុងសេចក្តីព្រាងច្បាប់នេះ កំណត់អំពីការគ្រប់គ្រងសុខភាពរុក្ខជាតិ ការអនុវត្តវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ ការពារធនធានរុក្ខជាតិគ្រប់ប្រភេទ ការទប់ស្កាត់ការបង្ក ការរាលដាលឆ្លង និងការរាតត្បាតពីសំណាក់សមាសភាពចង្រៃ ការលើកកម្ពស់ផលិតភាពកសិកម្មសន្តិសុខស្បៀងអនាម័យគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម។ សេចក្តីព្រាងច្បាប់នេះ ក៏នឹងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងវិស័យកសិកម្ម រួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

គោលបំណងនៃសេចក្តីព្រាងច្បាប់នេះ គឺផ្តោតសំខាន់លើការការពារផលប្រយោជន៍របស់ប្រជាកសិករគាំទ្រគោលនយោបាយ និងយុទ្ធសាស្ត្រជំរុញផលិតកម្មកសិកម្ម លើកកម្ពស់សុខភាពសាធារណៈ និងធ្វើឱ្យមាននិរន្តរភាពធនធានធម្មជាតិ និងប្រព័ន្ធអេក្បូត្របរិស្ថាន។ លើសនេះ ក៏ជួយទប់ស្កាត់ការហូរចូលកសិផលិតគ្រប់ប្រភេទ ដែលមានផ្ទុកនូវសមាសភាពចង្រៃ និងសារធាតុបង្កផលប៉ះពាល់សុខភាព។ ជាពិសេសទប់ស្កាត់ការនាំចូល ឬការផ្ទុះឡើងនូវប្រភេទសមាសភាពចង្រៃរាតត្បាតឈ្លានពាន ដែលបង្កមហន្តរាយដល់ដំណាំកសិកម្ម បំផ្លាញជីវចម្រុះ និងបរិស្ថានក្នុងប្រទេសកម្ពុជា ផងដែរ។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងអនុលោមតាមមូលដ្ឋានគតិយុត្តិពាក់ព័ន្ធជាធរមាននៅក្នុងប្រទេសកម្ពុជា ព្រមទាំងកិច្ចព្រៀង និងអនុសញ្ញាក្នុងតំបន់និងអន្តរជាតិ ស្តីពីការការពាររុក្ខជាតិ

និងកូតគាមអនាម័យ ដើម្បីឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្ម ក្នុងក្របខ័ណ្ឌសុវត្ថិភាពស្បៀង ការលើកកម្ពស់គុណភាពផលិតផលកសិកម្ម ការបង្កើនការនាំចេញកសិផល និងធានាចីរភាពអភិវឌ្ឍន៍ ក្នុងបរិការណ៍សមាហរណកម្មសេដ្ឋកិច្ចពិភពលោក ប្រកបដោយការប្រកួតប្រជែង៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២។*

## តម្លៃទីផ្សារដំឡូងមីមានការប្រែប្រួលយ៉ាងណាខ្លះ នៅដើមឆ្នាំ២០២២ ?



*ដោយ ខេមបូណ្ឌមីស*

ទីផ្សារដំឡូងមីនៅដើមឆ្នាំ២០២២ ហាក់មិនសូវមានការប្រែប្រួលខ្លាំងជាងឆ្នាំមុនប៉ុន្មាននោះទេ ខណៈដែលផ្ទៃដីដាំដុះក៏មានការកើនឡើតតិចតួចប៉ុណ្ណោះ។

ប្រទេសវៀតណាម នៅតែជាទីផ្សារចម្បងសម្រាប់ដំឡូងមីរបស់កម្ពុជា ខណៈដែលរោងចក្រកែច្នៃដំឡូងមីក្នុងស្រុកនៅមានចំនួនតិចតួចនៅឡើយ។

ប្រធានការិយាល័យសេត្តសាស្រ្តខេត្តរតនគិរី បានឱ្យដឹងថាទីផ្សារដំឡូងមីនៅឆ្នាំនេះ ហាក់មានតម្លៃប្រហាក់ប្រហែលនឹងឆ្នាំមុនដែរ ដែលជាមធ្យមដំឡូងមីស្រស់មានតម្លៃចន្លោះពី ៣២០ ទៅ ៣៨០ រៀលក្នុងមួយគីឡូក្រាម ចំណែកឯដំឡូងមីក្រៀមវិញមានប្រមាណ ៧៥០ រៀលក្នុងមួយគីឡូក្រាម តម្លៃនេះ គឺអាស្រ័យទៅលើគុណភាពដំឡូងមី និងទីតាំងរបស់ប្រជាកសិករ។

ចំពោះផ្ទៃដីដាំដំឡូងមី មានការកើនឡើងតិចតួចប៉ុណ្ណោះ ដោយសារកសិករមួយចំនួនបានដាំដំឡូងមីផង រួមទាំងដាំស្វាយចន្ទីផង ហើយដំឡូងមីជាដំណាំដែលខ្ជិជីដាំ មានន័យថាពួកគាត់មើលលើទីផ្សារថាតម្លៃមួយណាខ្ពស់ជាងមួយណា ប្រជាកសិករនឹងដាំដំណាំនោះច្រើនជាង។

ចំពោះខេត្តបាត់ដំបងវិញ តម្លៃទីផ្សារដំឡូងមីក្នុងឆ្នាំនេះ មានការកើនឡើងជាងឆ្នាំមុន។ គោលដៅនាំចេញដំឡូងមីនៅខេត្តបាត់ដំបង ប្រមាណ៧០% ត្រូវនាំចេញទៅប្រទេសថៃ និងប្រមាណ ៣០% ទៀតគឺសម្រាប់ប្រើប្រាស់ក្នុងស្រុក។

យោងតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បង្ហាញថា ការនាំចេញដំឡូងមី និងផលិតផលដំឡូងមី ក្នុងឆ្នាំ ២០២១ សម្រេចបានជិត ២,៨លានតោន។ ក្នុងនោះចំណិតដំឡូងមីក្រៀម មានជាង១៦,លានតោន កើនជាង៨%។ ដំឡូងមីស្រស់បាននាំចេញបានកើនជាង៥២%៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២។*

## ប្រទេសកម្ពុជា ទទួលបានចំណូលពីការនាំចេញស្រូវ-អង្ករ ជាង ៩៦លានដុល្លារត្រឹមរយៈពេល១ខែដំបូងនៃឆ្នាំ២០២២



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២២ រូបភាព៖ហេង ជីវ័ន*

យោងតាមទិន្នន័យសហព័ន្ធស្រូវ-អង្ករកម្ពុជា (CRF) វិស័យនាំចេញ ស្រូវ អង្ករកម្ពុជា ទទួលបានសញ្ញា

វិជ្ជមានដោយក្នុងខែមករា ឆ្នាំនេះ ការនាំចេញស្រូវ-អង្ករសម្រេចបានក្នុងតម្លៃ ៩៦លានដុល្លារ។

ត្រឹមរយៈពេល១ខែដំបូងឆ្នាំ ២០២២ កម្ពុជាបានធ្វើការនាំចេញអង្ករក្នុងបរិមាណជាង ៥៣ពាន់តោន ក្នុងតម្លៃ ៣៥,៧ លានដុល្លារ កើនឡើង ៥៥% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ ២០២១។ ទីផ្សារគោលដៅនាំចេញអង្កររបស់ប្រទេសកម្ពុជាមាន ៣៤ ប្រទេស ក្នុងនោះប្រទេសចិន និងតំបន់ស្វយ័តហុងកុង មានចំណែកធំជាងគេរហូតដល់ ៥៩% ប្រទេសចំនួន ១៦ ក្នុងទ្វីបអឺរ៉ុបមាន២៤% ប្រទេសចំនួន០៣ ក្នុងតំបន់អាស៊ានមាន ១២% និងគោលដៅផ្សេងៗមានចំនួន ៦%។

ដោយឡែកសម្រាប់ការនាំចេញស្រូវសម្រេចបាន ២៧,៥ ពាន់តោន គិតជាទឹកប្រាក់មានចំនួន ៦០,៦លានដុល្លារ ហើយការនាំចេញភាគច្រើន គឺទៅប្រទេសវៀតណាម។

នៅឆ្នាំ២០១៩គណៈកម្មការអឺរ៉ុបបានសម្រេចហូតពន្ធនាំចូលរយៈពេល ៣ ឆ្នាំលើអង្ករដែលនាំចេញពីប្រទេសកម្ពុជា និងមីយ៉ាន់ម៉ា តាមរយៈការអនុវត្តវិធានការការពារដោយសារការកើនឡើងការនាំចូលអង្ករប្រភេទ Indica ពីប្រទេសទាំង ២ ធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចបណ្តាប្រទេសផលិតអង្ករនៅអឺរ៉ុប។ តាមរយៈវិធានការនេះបានតម្រូវឱ្យកម្ពុជាត្រូវបង់ពន្ធនាំចូលចំនួន ១៧៥ អឺរ៉ូក្នុង ១ តោននៅឆ្នាំដំបូង (២០១៩) ,១៥០ អឺរ៉ូ នៅឆ្នាំទី២(២០២០) និង១២៥អឺរ៉ូ នៅឆ្នាំទី ៣ (២០២១) ។

ក្នុងឆ្នាំ២០២២ ការនាំចេញអង្ករត្រូវរំពឹងថានឹងមានកំណើនល្អប្រសើរឡើងវិញ បន្ទាប់ពីវិធានការរបស់សហភាពអឺរ៉ុបលើអង្ករកម្ពុជា ត្រូវបានបិទបញ្ចប់កាលពីថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២២, និងកត្តារួមផ្សំមួយចំនួនដូចជា ការផ្តល់កូតានាំចេញអង្ករទៅកាន់ប្រទេសចិន (៤០ ម៉ឺនតោន) និងសន្ទុះនៃការបញ្ជាទិញពីទីផ្សារអឺរ៉ុប។

សហព័ន្ធស្រូវអង្ករកម្ពុជាបានដាក់ផែនការនាំចេញអង្ករក្នុងចន្លោះពី ៨០-៨៥ ម៉ឺនតោន។ ម្យ៉ាងទៀត កម្ពុជានឹងទទួលបានអត្ថប្រយោជន៍ពីក្របខ័ណ្ឌ អនុគ្រោះពាណិជ្ជកម្មស្ថិតក្រោមផែនការទំនិញគ្រប់យ៉ាង លើកលែងតែអាវុធ (EBA) ដើម្បីប្រកួតប្រជែងនៅទីផ្សារសហភាពអឺរ៉ុបនៅក្នុងឆ្នាំ២០២២នេះ។

កាលពីឆ្នាំ ២០២១ កម្ពុជាបាននាំចេញអង្ករទៅគោលដៅសរុបចំនួន ៥៦ ប្រទេស និងតំបន់ក្នុងបរិមាណសរុបជាង៦១៧ ពាន់តោន គិតជាទឹកប្រាក់ចំនួន ៤១៨ លានដុល្លារ និងបាននាំស្រូវចេញចំនួនជាង ៣ ៥២៧ ពាន់តោនគិតជាទឹកប្រាក់ប្រមាណ ៨៤៦លានដុល្លារ៕ *ដោយ សេន ចន្ទ*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២*

## GDCE ដាក់បង្ហាញអត្រាពន្ធគយឆ្នាំ២០២២ នៅលើកម្មវិធីទូរស័ព្ទ



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២២ រូបភាព៖ ហេង ជីវ៉ន*

យោងតាមលោក គាម ចាន់កុសល អ្នកនាំពាក្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានឱ្យដឹងថា៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា(GDCE) បានដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទដៃឆ្លាតវៃតារាងពន្ធគយកម្ពុជាឆ្នាំ២០២២ ដើម្បីពង្រឹងប្រសិទ្ធភាពកិច្ចសម្រួលពាណិជ្ជកម្ម ក៏ដូចជាសម្រួលដល់ធុរជន ក្នុងការស្វែងរកចំណាត់ថ្នាក់ទំនិញ មុខទំនិញហាមឃាត់នានាបាន

ដោយងាយស្រួល និងការគណនាប្រាក់ពន្ធអាករនៃទំនិញដែលធុរជនចង់នាំចូលមកកម្ពុជា។

បន្ថែមពីនេះ ការបង្កើតកម្មវិធីទូរស័ព្ទឆ្លាតវៃក៏សម្រាប់ធ្វើការផ្សព្វផ្សាយពីការអនុវត្តតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ដែលត្រូវបានកែសម្រួលពីតារាងពន្ធគយឆ្នាំ ២០០៧ ដើម្បីឱ្យស្របទៅតាមប្រទេសជាសមាជិកអាស៊ានទាំង១០ និងសង្គតិភាពជាមួយបណ្តាប្រទេសទាំងអស់លើពិភពលោក ដែលជាសមាជិកនៃអង្គការគយពិភពលោក(WCO)។ ក្រៅពីនេះ កម្មវិធីនេះនឹងបង្កលក្ខណៈកាន់តែងាយស្រួលដល់ធុរជនក្នុងការបំពេញបែបបទនីតិវិធីពន្ធគយ ព្រមទាំងការទទួលបាននូវព័ត៌មានពីនីតិវិធីនៃការនាំចូលកាន់តែរហ័ស ចំណេញពេលវេលា និងថវិកា៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០២២*

## អភិបាលខេត្តបន្ទាយមានជ័យ បង្ហាញពីសក្តានុពលសេដ្ឋកិច្ច និងវិនិយោគដល់ទូតអាមេរិក



*ដោយ ៖ Kampucheathmey*

ខេត្តបន្ទាយមានជ័យ ស្ថិតនៅប៉ែកពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៣៥៩ គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានព្រំប្រទល់ជាប់ប្រទេសថៃ ប្រវែង ១៥៣ គម។ ខេត្តមានផ្ទៃដីសរុប ៦ ៦៧៩គីឡូម៉ែត្រការ៉េ ចែកចេញជា០២ ក្រុង ០៧ស្រុក ៥៥ឃុំ១០សង្កាត់ និង៦៥៨ ភូមិ មានប្រជាជនពលរដ្ឋ ប្រមាណ ៧៩ម៉ឺននាក់។ ក្នុងនោះមាន ៨៥% ប្រកបមុខរបរធ្វើស្រែចម្ការ និង១៥% ជាអាជីវករ ពាណិជ្ជករសិប្បករ កម្មករនៃសាទគ្រី និងចិញ្ចឹមសត្វ។

កាលពីថ្ងៃទី០៧ខែកម្ភៈឆ្នាំ២០២២ ប្រតិភូស្ថានទូតអាមេរិក បានទស្សនកិច្ចនៅលើទឹកដីខេត្តបន្ទាយមានជ័យ ក្នុងគោលបំណងសិក្សាស្វែងយល់អំពី សក្តានុពលរបស់ខេត្ត បញ្ហាការជួញដូរមនុស្សឆ្លងដែន សុខាភិបាល និងអប់រំ។ អភិបាលខេត្តបន្ទាយមានជ័យ បានរៀបរាប់បង្ហាញអំពី សក្តានុពលសេដ្ឋកិច្ច និងការវិនិយោគរបស់ខេត្ត ជូនដល់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជាថា ខេត្ត មានច្រកសេដ្ឋកិច្ចសំខាន់ៗ ចំនួន០៣ គឺច្រកអន្តរជាតិប៉ោយប៉ែត ច្រកទ្វារបឹងត្រកួន និងច្រកព្រំដែនម៉ាឡៃ។ ខេត្តក៏មានតំបន់សេដ្ឋកិច្ចពិសេស០៥កន្លែង នៅក្រុងប៉ោយប៉ែត គឺតំបន់សេដ្ឋកិច្ចពិសេសអូរនាង តំបន់សេដ្ឋកិច្ចពិសេសសានកូ តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែតភីភី តំបន់សេដ្ឋកិច្ចពិសេស លី អ៊ុតនីព្រមទាំងឧទ្យានឧស្សាហកម្ម០១កន្លែងនៅក្រុងសិរីសោភ័ណ។ នៅក្រុងប៉ោយប៉ែត មានក្រុមហ៊ុនជប៉ុនចំនួន ០៦កំពុងដំណើរការនៅតំបន់សេដ្ឋកិច្ចពិសេសសានកូ និង០១ក្រុមហ៊ុនទៀត នៅតំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែតភីភី ផលិតសម្ភារៈបរិក្ខាអេឡិចត្រូនិក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ kampucheathmey ចេញផ្សាយថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២។*

## កសិករនៅតែប្រឈមការលំបាកច្រើនក្នុងការដាំដុះស្វាយឲ្យត្រូវតាមស្តង់ដារនាំចេញ ហេតុអ្វី?



*ដោយ ខេមបូណ្ណមីស(សកម្មភាពកសិករប្រមូលផលផ្លែស្វាយ)*

ក្រុមប្រជាកសិករអះអាងថា ពួកគាត់នៅតែមិនទាន់យល់ច្បាស់អំពីស្តង់ដារនៃការដាំស្វាយនាំចេញទៅក្រៅប្រទេស ដូច្នេះហើយពួកគាត់នៅតែបន្តពឹងផ្អែកលើឈ្មួញកណ្តាល។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថា បញ្ហាប្រឈម គឺដោយសារតែពួកគាត់នៅមិនទាន់បានចងក្រងជាសហគមន៍ និងមិនមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងក្រុមហ៊ុននាំចេញស្វាយ ដូច្នេះហើយទើបពួកគាត់មិនអាចដាំដុះស្វាយបានត្រឹមត្រូវទៅតាមស្តង់ដារនាំចេញ។ ក្រសួង បានស្នើឱ្យប្រជាកសិករចងក្រងជាសហគមន៍ ជាបណ្តុំ និងសហការជាមួយក្រុមហ៊ុននាំចេញឱ្យបានល្អ ទើបអាចធ្វើការដាំដុះស្វាយអាចនាំចេញបាន។ ផ្លែស្វាយដែលអាចនាំចេញទៅទីផ្សារអន្តរជាតិបាន មិនត្រូវមានសំណល់ថ្នាំកសិកម្ម និងសមាសភាពចង្រៃ ដែលនៅក្នុងផ្លែស្វាយនោះ ពិសេសចាប់ពីការដាំដុះរហូតដល់ការធ្វើប្រព្រឹត្តកម្មស្វាយ។

ដូច្នេះ ការផ្សាភ្ជាប់ទំនាក់ទំនងរវាងអ្នកដាំស្វាយនិងក្រុមហ៊ុននាំចេញ នឹងបង្កើនឱកាសដល់កសិករទទួលបាននូវការបណ្តុះបណ្តាលបច្ចេកទេសសម្រាប់ផលិតកម្មស្វាយនាំចេញ និងធានាបាននូវស្ថិរភាពទីផ្សារ ផងដែរ។

ជុំវិញបញ្ហានេះ ក្រុមកសិករដាំស្វាយកែវរមៀត នៅខេត្តកំពង់ធំ បានគូសបញ្ជាក់ថា ដ្បិតបច្ចុបន្ន ក្រុមកសិករបានចងក្រងជាបណ្តុំសហគមន៍ និងកែសម្រួលបច្ចេកទេសដាំដុះ ក៏ពិតមែន តែមិនទាន់អាចដោះស្រាយបញ្ហាទីផ្សារបាននៅឡើយ ព្រោះក្រុមកសិករនៅតែពឹងផ្អែកលើឈ្មួញកណ្តាល ពិសេសមិនមានទំនាក់ទំនងជាមួយក្រុមហ៊ុននាំចេញស្វាយទៅទីផ្សារអន្តរជាតិ នោះទេដែលធ្វើឱ្យក្រុមកសិករ មិនទាន់យល់ច្បាស់ពីលក្ខខណ្ឌតម្រូវសម្រាប់នាំចេញ។

យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ នៅឆ្នាំ២០២១ កម្ពុជា បាននាំចេញផ្លែស្វាយស្រស់ ជាង២៤ម៉ឺនតោន ទៅកាន់ទីផ្សារសំខាន់ៗ ដូចជា វៀតណាម,ថៃ,ចិន,កូរ៉េខាងត្បូង ជាដើម។ បច្ចុប្បន្ន កម្ពុជា មានផ្ទៃដីដាំដុះស្វាយសរុបជាង ១០ម៉ឺនហិកតា និងទទួលបានទិន្នផលប្រមាណជិត២លានតោន ក្នុងមួយឆ្នាំ៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភពះខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២។*

## ពលរដ្ឋត្អូញត្អែរពីតម្លៃសាំងកាន់តែឡើងថ្លៃ ខណៈមន្ត្រីថាមិនអាចគ្រប់គ្រងបាន




*ដោយ Kampucheathmey*

អ្នកប្រកបរបរលក់ភេជ្ជៈតាមរ៉ឺម៉កម៉ូតូ បានលើកឡើងថា ក្នុង១ថ្ងៃលោក ចំណាយលុយចាក់សាំងម៉ូតូអស់ ៩ពាន់រៀល ស្មើនឹង២លីត្រ ដើម្បីធ្វើដំណើរទៅគ្រប់ទីកន្លែងលក់ភេសជ្ជៈ។ ការចំណាយទៅលើមធ្យោបាយធ្វើដំណើរខ្ពស់ ការលក់ដូរមិនសូវដាច់។ ប្រសិនបើប្រេងសាំងធ្លាក់ចុះ នៅត្រឹម ៣ ៥០០រៀល ក្នុង១លីត្រនោះ គឺល្អប្រសើរខ្លះ។

អ្នកលក់ដូងតាមរ៉ឺម៉កម៉ូតូ នៅក្បែរផ្សារបឹងកេងកង បានឱ្យដឹងថា សព្វថ្ងៃលោកត្រូវចំណាយ ១ថ្ងៃអស់ចន្លោះពី ២ម៉ឺនរៀល ទៅ ៣ម៉ឺនរៀល ទៅលើមធ្យោបាយធ្វើដំណើរ ដោយមិនគិតថ្លៃផ្ញើរ៉ឺម៉ក ម្ហូបអាហារ និងជួលផ្ទះ។ ចំពោះចំណូលមិនសូវជាបានល្អ តម្លៃប្រេងសាំងក៏ឡើង ធ្វើឱ្យចំណេញតិច។ លោក សូមឱ្យរាជរដ្ឋាភិបាលជួយទម្លាក់តម្លៃសាំងឱ្យមកនៅក្រោម ៤ពាន់រៀល។

ចំណែកអ្នករត់ម៉ូតូកង់បីក៏មិនខុសពីអ្នកទាំងពីរខាងលើដែរ។ លោកថា សាំងកាន់តែឡើងថ្លៃ មុខរបររត់ម៉ូតូកង់បីខ្មែរ បាត់បង់អតិថិជនជាងពាក់កណ្ដាល ធ្វើឱ្យជីវភាព ជួបការលំបាកខ្លាំង។

អ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម ឆ្លើយតបថា ប្រេងសាំងដែលចេះតែឡើងថ្លៃនេះ ដោយសារលកនៃអូមីក្រុង ធ្វើឱ្យបណ្ដាប្រទេសផលិតប្រេងមិនទាន់មានសេចក្ដីសម្រេចណាមួយ អំពីការបន្ថែមផលិតកម្មរបស់ខ្លួន ដើម្បីទប់ទល់ និងឆ្លើយតបតម្រូវការនៅឡើយ។ ដោយសារការផ្គត់ផ្គង់វាទាបជាងតម្រូវការ បានធ្វើឱ្យតម្លៃខ្ពស់។ យើងមិនទាន់សន្និដ្ឋានបានថា នឹងធ្លាក់ចុះនៅពេលណាបានឡើយ ដរាបណាប្រទេស ផលិតប្រេង និងប្រទេសធំៗ ដូចជាអាមេរិក និងចិនជាដើម ដែលមានស្តុកបម្រុងទុក មិនទាន់មានវិធានការណាមួយក្នុងការឆ្លើយតបនឹងរឿងនេះ។

ក្រសួងពាណិជ្ជកម្ម បានប្រកាសកាលពីថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០២២ថា តម្លៃប្រេងឥន្ទនៈ បានបន្តកើនឡើងជាបន្តបន្ទាប់ ក្នុងនោះតម្លៃប្រេងសាំងធម្មតាឡើង ១៥០ រៀល បន្ថែមទៀត ដែលនឹងត្រូវដាក់លក់ក្នុងតម្លៃ ៤ ៥០០ រៀល ក្នុង១លីត្រ ខណៈប្រេងម៉ាស៊ូត បានឡើង ២០០ រៀល ធ្វើឱ្យតម្លៃកើនដល់ ៤ ២០០ រៀល ក្នុង១លីត្រ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ Kampucheathmey ចេញផ្សាយថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសក្នុងខែវិច្ឆិកា ឆ្នាំ២០២១

ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថានៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១នេះ រដ្ឋបាលថ្នាក់ជាតិ បានប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសសរុបចំនួន ១៦០,៣៥ប៊ីលានរៀល កើនឡើងប្រមាណជា១១,៦% ធៀបនឹងខែតុលាឆ្នាំ២០២១។ ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចូលបានសរុបចំនួន ១៥៥,៦៧ប៊ីលានរៀល នៅក្នុងខែវិច្ឆិកាឆ្នាំ២០២១ កើនឡើងប្រហែលជា ១១,២% ធៀបនឹងខែតុលាឆ្នាំ២០២១។

ស្របពេលនោះដែរ ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញបានសរុបចំនួន ៤,៦៨ប៊ីលានរៀល នៅក្នុងខែវិច្ឆិកាឆ្នាំ២០២១ កើនឡើងប្រហែលជា ៣៨,៤% ធៀបនឹងខែតុលាឆ្នាំ២០២១៕

*ដោយ៖ មិត្ត ចន្ទី*

*ប្រភព៖តារាងប្រតិបត្តការហិរញ្ញវត្ថុសម្រាប់ខែវិច្ឆិកា ឆ្នាំ២០២១នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

| បរិយាយ(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| **ចំណូលពន្ធលើ ពាណិជ្ជកម្មក្រៅប្រ ទេស** | **159.53** | **153.14** | **238.52** | **106.6** | **186.59** | **188.32** | **158.76** | **150.23** | **180.82** | **143.62** | **160.35** |
| កំណើន(%) | | -4.0% | 55.8% | -55.3% | 75.1% | 0.9% | -15.7% | -5.4% | 20.4% | -20.6% | 11.6% |
| ពន្ធ និងអាករលើការនាំចូល | 156.89 | 150.79 | 233.60 | 103.46 | 182.84 | 185.37 | 155.13 | 146.69 | 178.32 | 140.04 | 155.67 |
| កំណើន(%) | | -3.9% | 54.9% | -55.7% | 76.7% | 1.4% | -16.3% | -5.4% | 21.6% | -21.5% | 11.2% |
| ពន្ធ និងអាករលើការនាំចេញ | 2.64 | 2.35 | 4.92 | 3.12 | 3.75 | 2.95 | 3.63 | 3.54 | 2.5 | 3.58 | 4.68 |
| កំណើន(%) | | -11.0% | 109.4% | -36.6% | 20.2% | -21.3% | 23.1% | -2.5% | -29.4% | 43.2% | 30.7% |

### តារាងទី២៖ពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិកលើមុខទំនិញនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថា៖ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុបចំនួន ៨២៥,៧លានដុល្លារ ធ្លាក់ចុះប្រមាណជា ២៤,៣% ធៀបនឹងខែតុលា ឆ្នាំ២០២១។

ជាក់ស្តែង ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិកមកកម្ពុជា មានទំហំទឹកប្រាក់សរុប ៣១,៥លានដុល្លារនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ធ្លាក់ចុះប្រមាណជា២៦,៩% ធៀបនឹងខែតុលា ឆ្នាំ២០២១។ ការនាំចូលទំនិញសំ

ខាន់ៗទាំងនេះរួមមាន៖ រថយន្តធ្វើដំណើរ គ្រឿងបន្លាស់រថយន្ត ទឹកដោះគោ ក្រែម និងផលិតផលផ្សេងៗទៀត។

ដោយឡែក ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុប ៧៩៤,២លានដុល្លារ នៅក្នុងខែវិច្ឆកា ឆ្នាំ២០២១ ធ្លាក់ចុះប្រមាណជា ២៤,២% ធៀបនឹងខែតុលា ឆ្នាំ២០២១។ ការនាំចេញនេះ ភាគច្រើនជាប្រភេទទំនិញរួមមាន៖ ចង្កៀងនិងគ្រឿងបំភ្លឺអគ្គិសនី កាបូបយួរ កាបូបលុយ សំលៀកបំពាក់ និងផលិតផលផ្សេងៗទៀត។ *ដោយ មិត្ត ចន្នី*

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **614.5** | **572.7** | **782.1** | **685.7** | **650.3** | **534.9** | **693.9** | **965.1** | **980.2** | **1091.3** | **825.7** |
| កំណើន % | | -6.8% | 36.6% | -12.3% | -5.2% | -17.8% | 29.7% | 39.1% | 1.6% | 11.3% | -24.3% |
| នាំចូល | 33.9 | 33.3 | 39.1 | 29.4 | 38.1 | 28.8 | 33.2 | 43.0 | 24.8 | 43.1 | 31.5 |
| កំណើន % | | -1.8% | 17.4% | -24.8% | 29.6% | -24.4% | 15.3% | 29.5% | -42.3% | 73.8% | -26.9% |
| នាំចេញ | 580.6 | 539.4 | 743.0 | 656.3 | 612.2 | 506.1 | 660.7 | 922.1 | 955.4 | 1048.2 | 794.2 |
| កំណើន % | | -7.1% | 37.7% | -11.7% | -6.7% | -17.3% | 30.5% | 39.6% | 3.6% | 9.7% | -24.2% |

ប្រភព៖ការិយាល័យជំរឿនសហរដ្ឋអាមេរិក និង ទិន្នន័យណិជ្ជកម្មសហរដ្ឋអាមេរិក

(គិតជាលានដុល្លារ)

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការលក់រថយន្តថ្មីក្នុងតំបន់អាស៊ានកំពុងកើនឡើងខ្ពស់ជាលើកដំបូង ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ




*ដោយ ខេមបូណ្ណមីស*

ការលក់រថយន្តថ្មីនៅក្នុងប្រទេសឥណ្ឌូនេស៊ី ថៃ ម៉ាឡេស៊ី វៀតណាម ហ្វីលីពីន និងសិង្ហបុរីមានចំនួនសរុបជិត ៣ លានគ្រឿងកាលពីឆ្នាំ២០២១ កើនឡើង ១៤% បើធៀបនឹងឆ្នាំ ២០២០។

ប្រទេសឥណ្ឌូនេស៊ី បានក្លាយជាទីផ្សារដ៏ធំបំផុតសម្រាប់ការលក់រថយន្តថ្មីនៃប្រទេសសេដ្ឋកិច្ចធំៗទាំង៦នៅអាស៊ាន ដោយបានលក់រថយន្តថ្មីបានចំនួនប្រមាណ ៩ សែន គ្រឿងក្នុងមួយឆ្នាំ*ដល់ទៅ ៦៧%*។ ក្នុងនោះ ក្រុមហ៊ុន Toyota Motor មានចំណែកទីផ្សារធំជាងគេដល់ទៅ ៣០% បន្ទាប់មក គឺ Daihatsu Motor និង Mitsubishi Motors នេះដោយសារតែមានការបន្ធូរបន្ថយការរឹតបន្តឹងនៃជំងឺ COVID-១៩ នៅក្នុងឆមាសទី២នៃឆ្នាំ២០២១។ ក៏ប៉ុន្តែ បើធៀបនឹងឆ្នាំ២០១៩ គឺមានតិចជាង ២០%នៅគ្រាមុនពេលជំងឺរាតត្បាតបានផ្ទុះឡើង។ សម្រាប់ឆ្នាំ២០២២ អាចនឹងមិនសូវមានកំណើន ដោយសារមានការរឹតត្បិត COVID-19កាន់តែតឹងរ៉ឹងនៅក្នុងតំបន់ទាំងមូល និងការរអាក់រអួលផលិតកម្មដែលបណ្តាលមកពីកង្វះខាតបន្ទះឈីប។ ក្នុងឆ្នាំ២០១៩ រថយន្តថ្មីត្រូវបានលក់ចេញប្រមាណ ១ លានគ្រឿង។

បើក្រឡេកមើលនៅប្រទេសថៃវិញ ក្នុងរយៈពេលបីឆ្នាំជាប់គ្នាការលក់រថយន្តថ្មីបានធ្លាក់ចុះមកនៅត្រឹមជាង ៧ សែន បានធ្លាក់ចុះ ៤%។ កាលពីឆមាសទី១ ឆ្នាំ២០២១ ការលក់រថយន្តថ្មីរបស់ថៃបានកើនឡើងវិញបណ្តើរៗ ប៉ុន្តែក៏ថមថយមកវិញ បន្ទាប់ពីការបិទខ្ទប់នៅទីក្រុងបាងកក និងទីក្រុងផ្សេងទៀតក្នុងខែកក្កដា និងក៏ដោយសារកង្វះខាតបន្ទះឈីប និងគ្រឿងបន្លាស់រថយន្តផ្សេងទៀត ដែលបង្ខំឱ្យក្រុមហ៊ុនផលិតរថយន្តជាច្រើនត្រូវផ្អាកការផលិត។ ប្រធានក្រុមហ៊ុន Toyota Motor Thailand បានអះអាងថា ឧស្សាហកម្មរថយន្ត

ថៃកំពុង "ផ្លាស់ប្តូរបន្តិចម្តងៗឆ្ពោះទៅរកភាពប្រក្រតី" ហើយបានព្យាករណ៍ថា នៅឆ្នាំ២០២២ការលក់រថយន្តនៅក្នុងប្រទេសនេះ នឹងមានប្រមាណ ៩ សែនគ្រឿង រួមទាំងរថយន្តដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនផលិតរថយន្តផ្សេងទៀតផងដែរ។ ប៉ុន្តែដោយសារការទិញថយចុះព្រោះវិបត្តិកូវីដ១៩អូសបន្លាយ ដូច្នេះការលក់រថយន្ត ទំនងជាមិនត្រលប់ទៅដូចកាលពីឆ្នាំ ២០១៩ ដែលលក់បានដល់ ១ លានគ្រឿងនោះទេ។ ពោលគឺត្រូវរង់ចាំរហូតដល់ក្រោយឆ្នាំ ២០២៣ទើបអាចសម្រេចបាន។

ចំពោះប្រទេសវៀតណាម និងហ្វីលីពីន ការលក់បានកើនឡើងក្នុងរយៈពេល ២ ឆ្នាំ ដោយវៀតណាមលក់បាន ៣០ម៉ឺនគ្រឿង កើន៣% និងហ្វីលីពីន បានជាង ២៨ម៉ឺនគ្រឿង កើន១៦%។ ដោយឡែក ប្រទេសម៉ាឡេស៊ីវិញ ការលក់បានថយចុះ២ឆ្នាំជាប់គ្នា ក្នុងឆ្នាំ ២០២១ ធ្លាក់ចុះ ៤%។ ក្រុមហ៊ុន ផលិតរថយន្តនៅម៉ាឡេស៊ី ក៏កំពុងជួបបញ្ហាដូចក្រុមហ៊ុននៅប្រទេសផ្សេងទៀតដែរ គឺកំពុងតែខ្វះខាតបន្ទះឈីបសម្រាប់ការផលិត ដែលជាកត្តាធ្វើឱ្យការលក់ធ្លាក់ចុះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២។*

## ធនាគារកណ្តាលថៃ នឹងអាចបន្តរក្សាអត្រាការប្រាក់ នៅអត្រា ០,៥% នៅឆ្នាំ២០២២នេះ




*ប្រភព៖ Times of India ២០២១*

ក្នុងការដេកស្រង់មតិទៅលើអ្នកសេដ្ឋកិច្ចចំនួន ២៣រូប របស់ Reuters ថ្មីៗនេះ រំពឹងថា ធនាគារកណ្តាលថៃ នឹងអាចសម្រេចបន្តអត្រាការប្រាក់ការទិញឡើងវិញប្រចាំថ្ងៃរបស់ខ្លួននៅដដែល ក្នុងអត្រាទាប ០,៥% ហើយនឹងបន្តអត្រានេះ រហូតដល់ដំណាច់ឆ្នាំ២០២២។ ការសម្រេចនេះ ដើម្បីធ្វើការជួយគាំទ្រដល់សេដ្ឋកិច្ចដែលរងការប៉ះទង្គិចយ៉ាងខ្លាំងពីវិបានវិតត្បិតលើការធ្វើដំណើរពាក់ព័ន្ធនឹងវិបត្តិជំងឺកូវីដ-១៩។ បច្ចុប្បន្ន អត្រាអតិផរណាក្នុងប្រទេសថៃ មានស្ថានភាពខ្ពស់ជាងអត្រាគោលដៅ ដែលកំណត់ក្នុងចន្លោះ ១% ទៅ៣% ក៏ប៉ុន្តែ អត្រានេះ ត្រូវបានរំពឹងថា នឹងត្រលប់ទៅរកកម្រិតគោលដៅវិញ នៅប៉ុន្មានខែខាងមុខ។

គួរបញ្ជាក់ថា សេដ្ឋកិច្ចប្រទេសជាសមាជិកអាស៊ាន នៅមិនទាន់ត្រលប់ទៅរកកម្រិតមុនវិបត្តិនោះឡើយ ហើយដំណើរនៃការងើបឡើងវិញនៃសេដ្ឋកិច្ច នៅមានភាពផុយស្រួយ ដោយសារតែការផ្ទុះឡើងនេះវីរុសបំប្លែងថ្មីអូមីក្រុង ដែលបានប៉ះទង្គិចយ៉ាងខ្លាំងលើឧស្សាហកម្មទេសចរណ៍។

ទន្ទឹមនេះដែរ អត្រាការប្រាក់គោល ត្រូវបានរំពឹងថា នឹងកើនឡើងទៅ ០,៧៥% ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ និង ១% នៅត្រីមាសទី៤ ឆ្នាំ២០២៣។

ដោយឡែក ចំពោះអតិផរណាវិញ ឃើញថា នឹងស្ថិតក្នុងអត្រាជាមធ្យម ១,៥% សម្រាប់ឆ្នាំនេះ និង ១,២% នៅឆ្នាំ២០២៣ យោងតាមការធ្វើស្ទង់មតិសេដ្ឋវិទូមួយផ្សេងទៀតរបស់ Reuters។ សេដ្ឋកិច្ចថៃ ឆ្នាំ២០២២ ត្រូវបានរំពឹងថា នឹងមានកំណើន ៣,៩% និងបន្តកំណើន ៤,១% នៅឆ្នាំក្រោយ៕ *ដោយ ដា សិរីរតន៍*

*ប្រភព៖ ការិយាល័យព័ត៌មានជាតិថៃ ចេញផ្សាយថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២*

## ពាណិជ្ជកម្មអន្តរជាតិឡាវ មានអតិរេកសរុប ១ប៊ីលានដុល្លារ ក្នុងឆ្នាំ២០២១



*ប្រភព៖ The Star ២០២២*

សម្រាប់ឆ្នាំ២០២១ ការនាំចេញ និងការនាំចេញសរុបរបស់ប្រទេសឡាវ មានចំនួន ១៣ប៊ីលានដុល្លារ(មិនគិតបញ្ចូលការនាំចេញ អគ្គិសនី) និងសម្រេចបានអតិ-រេក ១ប៊ីលានដុល្លារ។ ក្នុងនោះ ការនាំចេញ មានទំហំសរុប ៧ប៊ីលានដុល្លារ ខណៈដែលទំហំការនាំចូល មានចំនួន ៦ប៊ីលានដុល្លារ។

ការនាំចេញចម្បងរបស់ឡាវរួមមាន រ៉ែមាស និងដុំមាស, ក្រដាស និងផលិតផលពីក្រដាស, ឈើ និងក្រដាសសំណល់, កៅស៊ូ, ដំឡូងមី, រ៉ែដែក, ចេក, សម្លៀកបំពាក់, គ្រឿងអគ្គិសនី និងឧបករណ៍អគ្គិសនី, ជី, គ្រឿងបន្លាស់កាមេរ៉ា, និងស្បែកជើង។ ចំណែកការនាំចូលចម្បងវិញ រួមមាន យានយន្ត(មិនគិតបញ្ចូល ម៉ូតូ និងត្រាក់ទ័រ), ប្រេងម៉ាស៊ូត, ឧបករណ៍មេកានិច(មិនរាប់បញ្ចូលយានជំនិះម៉ូតូ), ត្បូងមានតម្លៃ ឬគ្រឿងបន្លាស់(រួមទាំងផ្លាស្ទិច កញ្ចក់ និងប្រវាក់), ដែកថែប និងផលិតផលពីដែកថែប និងម៉ាញេទិក, ផលិតផលឱសថ, ផលិតផលប្លាស្ទិក, គ្រឿងអគ្គិសនី, ប្រេងសាំង, សំណល់អេតចាយ និងកាកសំណល់ពីអាហារ, ឧបករណ៍កាមេរ៉ា, និងឈើ និងផលិតផលពីឈើ។

គួរបញ្ជាក់ថា ប្រទេសចិន គឺជាដៃគូនាំចេញធំបំផុតរបស់ឡាវ បន្ទាប់មកគឺ ថៃ វៀតណាម អូស្ត្រាលី និងស្វីស។ ដោយឡែក ឡាវបានធ្វើការនាំចូលច្រើនជាងគេពី ថៃ និងបន្ទាប់មក ចិន វៀតណាម សហរដ្ឋអាមេរិក និងជប៉ុន៕ *ដោយ ជា សិរីរតន៍*

*ប្រភព៖ The Star ចេញផ្សាយថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២*

## តុល្យភាពទូទាត់របស់ជប៉ុនក្នុងខែធ្នូឆ្នាំ២០២១

តុល្យភាពគណនីចរន្តរបស់ជប៉ុនមានឱនភាពរហូតដល់ ៣៧០,៨ ប៊ីលានយ៉េន នៅក្នុងខែធ្នូ ឆ្នាំ២០២១ ពីអតិរេកចំនួន ១ ១១៦,៥ប៊ីលានយ៉េននៅក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០ និងការរំពឹងទុកពីទីផ្សារថានិងមានអតិរេកចំនួន ៧៣,៨ប៊ីលានយ៉េន។ ក្នុងនោះ គណនីទំនិញមានឱនភាព ៣១៨,៧ប៊ីលានយ៉េន ពីអតិរេកចំនួន ៩៦៥ ប៊ីលានយ៉េន ខណៈការនាំចេញកើនឡើង ១៨,៧% និងការនាំចូលកើនឡើង៤៤,៨%។ ទន្ទឹមនឹងនេះ គណនីសេវាកម្មមានឱនភាព ៣២១,៣ ប៊ីលានយ៉េន និងចំណូលបន្ទាប់បន្សំបានកើនឡើងរហូតដល់ ១២៩,៥ប៊ីលានយ៉េន ពី ១០៩,១ប៊ីលានយ៉េន។ ស្របពេលជាមួយគ្នានេះដែរអតិរេកចំណូលបឋមបានធ្លាក់ចុះដល់ ៣៩៨,៨ប៊ីលានយ៉េនពីអតិរេកចំនួន ៥៧៣,៤ប៊ីលានយ៉េនកាលពីឆ្នាំកន្លងទៅ៕ *ដោយមុំ ចិន្តា*

**តារាងតុល្យភាពនៃការទូទាត់របស់ជប៉ុន(គិតជាប៊ីលានយ៉េន)**

| បរិយាយ | ចំនួន | កំណើនពីមួយឆ្នាំទៅមួយឆ្នាំ | |
|---|---|---|---|
| តុល្យភាពពាណិជ្ជកម្ម និងសេវាកម្ម | (640) | (1,292.2) | |
| តុល្យភាពពាណិជ្ជកម្ម | (318.7) | (1,283.7) | |
| ការនាំញ | 7,797.2 | 1,229.1 | 18.7% |
| ការនាំចូល | 8,115.9 | 2,512.8 | 44.8% |
| តុល្យភាពសេវាកម្ម | (321.3) | (8.5) | |
| តុល្យភាពចំណូលបឋម | 398.8 | (174.6) | |
| តុល្យភាពចំណូលបន្ទាប់បន្សំ | (129.5) | (20.5) | |
| តុល្យភាពគណនីចរន្ត | (370.8) | (1,487.3) | |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជប៉ុន*

## សិង្ហបុរីក្លាយជាអ្នកវិនិយោគ បរទេសធំបំផុតរបស់មីយ៉ាន់ម៉ា៤ខែ ចុងក្រោយឆ្នាំទៅ



*ដោយ ៖ dap-news*

ប្រទេសសិង្ហបុរីបានក្លាយទៅជាអ្នកវិនិយោគបរទេសច្រើនបំផុត របស់មីយ៉ាន់ម៉ាក្នុងរយៈពេល៤ខែចុងក្រោយ កាលពីឆ្នាំទៅគិតចាប់ពីខែតុលាមក។ មីយ៉ាន់ម៉ាអាចទាក់ទាញយកការវិនិយោគពីសិង្ហបុរី ក្នុងទំហំទឹកប្រាក់ប្រមាណជា៥០៦លានដុល្លារ ដែលក្នុងនោះសេវាកម្មឯកជនមានទំហំ ប្រមាណជា២០៦លានដុល្លារ វិស័យផលិតកម្មប្រមាណជា១១៤លានដុល្លារ និងវិស័យសំណង់ប្រមាណ ជា៦៤លានដុល្លារ។ ក្នុងឆ្នាំសារពើពន្ធកាលពីឆ្នាំមុន មីយ៉ាន់ម៉ាអាចរកចំណូលបានរហូតទៅដល់ ៣ ៧០០លានដុល្លារ ពីបណ្ដាក្រុមហ៊ុនឯកជនបរទេសទាំងឡាយ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ dap-news ចេញផ្សាយថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២។*

## ជប៉ុនត្រូវការពលករបរទេស៦លាននាក់នៅឆ្នាំ២០៤០



*ដោយ ខេមបូណ្ឌូមីស*

ចំនួនកម្មករបរទេសនៅជប៉ុន អាចនឹងមានការធ្លាក់ទាបជាងមុន ៤២ម៉ឺននាក់នៅឆ្នាំ ២០៤០ ព្រោះនៅបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ជាច្រើននឹងមានកំណើនប្រជាជនវ័យចំណាស់ ហើយនឹងចំនួនប្រជាជនក៏នឹងថយចុះផងដែរ។ គោលនយោបាយហាមប្រាមអន្តោប្រវេសន៍របស់ជប៉ុន អាចបង្កការលំបាកដល់ការទាក់ទាញពលករបរទេស។ ដូច្នេះជប៉ុន នឹងជួបឧបសគ្គក្នុងការទាក់ទាញពលករបរទេស ដែលអាចនឹងប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរបស់ជប៉ុន។

ប្រទេសជប៉ុនគ្រោងនឹងត្រូវការពលករបរទេសជាង ៦,៧លាននាក់បន្ថែមទៀត គឺច្រើនជាង ៤ ដងនៃចំនួនដែលមានសព្វថ្ងៃនេះ។ ការព្យាករណ៍ទាំងនេះ គឺផ្អែកលើការប៉ាន់ប្រមាណទាក់ទងនឹងអត្រាកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសជប៉ុន និងប្រទេសដទៃទៀត។ កន្លងមកជប៉ុនបានជួបបញ្ហាខ្វះខាតកម្លាំងពលកម្មយ៉ាងធ្ងន់ធ្ងរ ជាពិសេសក្នុងវិស័យ កសិកម្ម សំណង់ និងផលិតកម្ម ដូចនេះហើយទើបជប៉ុនបង្កើនកិច្ចខិតខំប្រឹងប្រែងទាក់ទាញកម្មករបរទេសបន្ថែមទៀត។ តាមគម្រោង នៅឆ្នាំ ២០៤០ វៀតណាមអាចនឹងនៅតែជាប្រភពកម្លាំងពលកម្មដ៏ធំបំផុតសម្រាប់ជប៉ុន ដែលរួមចំណែកដល់ទៅ ២៨% នៃពលករបរទេសទាំងអស់ ហើយក៏មានពលករពីប្រទេសផ្សេងបន្ថែមទៀតដែរ រួមមាន មីយ៉ាន់ម៉ា កម្ពុជា បង់ក្លាដែស នេប៉ាល់ និងឥណ្ឌា។ រីឯ ពលករដែលមកពីប្រទេសចិន និងថៃ អាចនឹងមានចំនួនតិចជាងមុន។

គិតត្រឹមចុងខែតុលា ឆ្នាំ២០២១ ជប៉ុនមានពលករបរទេសកំពុងបម្រើការជាង១,៧លាននាក់ ក្នុងនោះរួម ៣៥ម៉ឺននាក់ គឺជាពលករស្ថិតក្រោមកម្មវិធីបណ្តុះបណ្តាលដែលអនុម័តដោយរាជរដ្ឋាភិបាលជប៉ុន និងមាន២២ម៉ឺននាក់ទៀត គឺជាអ្នកធ្វើការក្រៅម៉ោង ដែលភាគច្រើនជានិស្សិតបរទេស។

ជប៉ុននឹងធ្វើការវិនិយោគលើបច្ចេកវិទ្យាកាន់តែច្រើនថែមទៀត ដើម្បីកាត់បន្ថយការប្រើប្រាស់កម្លាំងមនុ

ស្ស។ បើគ្មានការវិនិយោគបែបនេះទេ តម្រូវការសម្រាប់កម្លាំងពលកម្មបរទេសនឹងកាន់តែរីកធំ ពោលគឺអាចនឹងហក់ឡើងរហូតដល់២១លាននាក់ក្នុងឆ្នាំ២០៤០។

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២។*

## សេដ្ឋកិច្ចសកល

### ចិនថា ការដំឡើងពន្ធរបស់អាមេរិកលើផលិតផលសូឡា ប៉ះពាល់ដល់ពាណិជ្ជកម្មវិស័យថាមពល



*ដោយ ខេមបូណ្ឌមីស*

ប្រធានាធិបតីអាមេរិក Joe Biden កាលពីថ្ងៃសុក្រសប្តាហ៍មុន បានចុះហត្ថលេខាបន្តការយកពន្ធដែលបានអនុវត្តជំនាន់លោក ដូណាល់ ត្រាំ នៅជាប្រធានាធិបតីលើឧបករណ៍ថាមពលពន្លឺព្រះអាទិត្យ ដែលនាំចូលពីប្រទេសចិនទាំងអស់ សម្រាប់រយៈពេល៤ឆ្នាំទៀត។ ការបន្តពន្យាសុពលភាព លើនាំងពន្ធគយពីសហរដ្ឋអាមេរិក មកលើផលិតផលថាមពលសូឡារបស់ចិន បានធ្វើឱ្យខូចខាតដល់ពាណិជ្ជកម្មចិនជាអន្តរជាតិ ហើយព្រមទាំងបានរារាំងដល់ការអភិវឌ្ឍថាមពលបៃតង ប៉ះពាល់ដល់គោលនយោបាយបញ្ចេញឧស្ម័នកាបូនកំរិតទាបថែមទៀតផង។ គេនៅចាំបានថា កាលនៅឆ្នាំ២០១៨អាមេរិកបានផ្តើមបន្ថែមពន្ធលើការនាំចូលផលិតផលបន្ទះសូឡាពីប្រទេសចិនក្នុងអត្រា ៣០% លុះក្រោយមក ចុះមកនៅត្រឹម ១៥%វិញ។ សហរដ្ឋអាមេរិក នៅតែបន្តសុពលភាពនៃការបន្ថែមពន្ធលើផលិតផលសូឡារបស់ចិន ដោយមិនបានអើពើ នឹងការទាមទារ ការប្រឆាំងពីភាគីពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេសនោះឡើយ។ សម្រាប់ប្រទេសចិន ប្រការនេះមិនត្រឹមតែបានធ្វើឱ្យប៉ះពាល់ដល់ពាណិជ្ជកម្មចិនទេតែ វាក៏នឹងធ្វើឱ្យខូចខាតដល់វិស័យថាមពលសូឡានៅសហរដ្ឋអាមេរិកខ្លួនឯង ព្រមទាំងពាណិជ្ជកម្មជាអន្តរជាតិផងដែរ។ ហើយសង្ឃឹមថា សហរដ្ឋអាមេរិកនឹងចាត់វិធានការទៅតាមតថភាពជាក់ស្តែង ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្មសេរី លើផលិតផលថាមពលថ្មីៗ ក៏ដូចជារួមចំណែកដល់ការអភិវឌ្ឍជាសកលនូវសេដ្ឋកិច្ចដែលដើរដោយឧស្ម័នផ្ទះកញ្ចក់កំរិតទាប។ ដោយសារការកើនឡើងនូវគោលនយោបាយគាំពារនិយមរបស់អាមេរិក បច្ចុប្បន្នក្រុមហ៊ុនផលិតថាមពលពន្លឺព្រះអាទិត្យរបស់ប្រទេសចិន បានផ្តោតសំខាន់កាន់តែខ្លាំងទៅលើទីផ្សារក្នុងស្រុកវិញ។ សមត្ថភាពផលិតថាមពលពន្លឺព្រះអាទិត្យរបស់ប្រទេសចិនបានកើនឡើងក្នុងកំណត់ត្រាថ្មី គឺបានកើតឡើងជិត៥៥ជីហ្គាវ៉ាត់ (GW)បន្ថែមទៀតកាលពីឆ្នាំមុន ធ្វើឱ្យសមត្ថភាពផលិតសរុបហក់ឡើងដល់ជាង ៣០៦ ឌីហ្គាវ៉ាត់។ ជាមួយគ្នានេះ ចិនមានគោលដៅផលិតថាមពលកកើតពីកម្លាំងខ្យល់បក់ និងថាមពលពន្លឺព្រះអាទិត្យសរុបឲ្យបានដល់ទៅ ១.២០០ GW នៅត្រឹមឆ្នាំ២០៣០។

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២។*

### ទីផ្សារការងារអាមេរិកកើនឡើង ខណៈអូមីក្រុងថមថយ



*មនុស្សម្នាកំពុងឈរតម្រង់ជួរដើម្បីចូលរួមពិព័ណ៌ការងារ Nassau County Mega Job Fair នៅ Nassau Veterans Memorial Coliseum ក្នុង Uniondale ទីក្រុង New York កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៤។ រូបថត៖ REUTERS/Shannon Stapleton/File Photo*

កាលពីខែមករាកន្លងទៅនេះ អត្រាអ្នកមានការងារធ្វើនៅសហរដ្ឋអាមេរិកបានកើនឡើងលើសពីការរំពឹងទុក។ កាលពីខែមករា ឆ្នាំ២០២២ ប្រាក់ឈ្នួលកើនឡើង ខណៈដែលកម្លាំងពលកម្មក៏មានការកើនឡើងដែរ។ ការងារមិនមែនកសិកម្មបានកើនឡើងចំនួន ៤៦៧,០០០កន្លែង លើសពីការព្យាករណ៍ក្រុមសេដ្ឋវិទូរបស់ Reuters ដែលរំពឹងថា នៅក្នុងខែមករា អ្នកមានការងារធ្វើនៅសហរដ្ឋអាមេរិកនឹងកើនឡើង ១៥០,០០០កន្លែងប៉ុណ្ណោះ។ យោងតាមទិន្នន័យាក់ស្តែងចំនួនអ្នកមានការងារនៅសហរដ្ឋអាមេរិកមានចំនួន ២,៩លានកន្លែងទាបជាងស្ថានភាពមុនកូវីដ-១៩។

ភាពធន់នៃទីផ្សារការងារអាចនឹងផ្លាស់ប្តូរការរំពឹងទុក ឬការព្យាករណ៍អំពីកំណើនសេដ្ឋកិច្ចថា នឹងអាចមានកំណើនយឺតខ្លាំងនៅក្នុងត្រីមាសទី១ បន្ទាប់ពីអ្នកប្រើប្រាស់បានកាត់បន្ថយចំណាយយ៉ាងគំហុកនៅក្នុងឆ្នាំ២០២១។ ប៉ុន្តែនៅក្នុងត្រីមាសទី៤ សេដ្ឋកិច្ចមានកំណើន ៦,៩% ខណៈដែលការព្យាករណ៍កំណើនសេដ្ឋកិច្ចសម្រាប់ត្រីមាសទី១ ទាបជាង ២% ប៉ុណ្ណោះ។ ដោយសារអត្រាអ្នកមានការងារបានធ្វើហក់ឡើងខ្ពស់ គួបផ្សំនឹងប្រាក់ឈ្នួលមានកំណើនខ្លាំងចាប់ពីពីខែមិនា ឆ្នាំ២០២០ បានជម្រុញឱ្យធនាគារកណ្តាលរបស់សហរដ្ឋអាមេរិកដំឡើងអត្រាការប្រាក់ដើម្បីទប់ទល់នឹងការកើនឡើងនៃអតិផរណា។

យោងតាមទិន្នន័យរបស់រដ្ឋាភិបាលកាលពីខែមិនា ឆ្នាំ២០២១ ការឈប់សម្រាកឈឺដោយមានប្រាក់ឈ្នួលមានដល់ទៅ ៧៩% នៃកម្មករនយោជិកស៊ីវិល។ ទោះយ៉ាងណា ការងារនៅក្នុងវិស័យឧស្សាហកម្មកំសាន្ត និងបដិសណ្ឋារកិច្ចបានកើនឡើងចំនួន ១៥១, ០០០កន្លែង នៅក្នុងខែមករា។ ចំណែកឯការងារក្នុងវិស័យសុខាភិបាលកើនឡើង ១៨,០០០ កន្លែង។ រីឯសកម្មភាពសេដ្ឋកិច្ចនៅក្នុងវិស័យលក់រាយ លក់ដុំ និងការផ្តល់សេវាជំនាញវិជ្ជាជីវៈផ្នែកពាណិជ្ជកម្មក៏ដូចជាវិស័យដឹកជញ្ជូន និងស្តុកមានការកើនឡើងគួរឱ្យកត់សំគាល់។ ដូចនេះអត្រាមានការងារធ្វើអាចនឹងកើនឡើងបន្តទៅទៀត ដោយសារតែការឆ្លងរីករាលដាលជំងឺកូវីដ១៩ កាន់តែមានភាពធូរស្រាលជាងមុន។ យោងតាមការវិភាគរបស់ Reuters ការឆ្លងរីករាលដាលកូវីដ១៩ នៅសហរដ្ឋអាមេរិកនឹងធ្លាក់ចុះជាង ៧០០,០០០ នៅពាក់កណ្តាលខែមករា ឆ្នាំនេះ។ *ដោយ **វង្ស ច័ន្ទរស្មីដារា***

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២*

## កិច្ចចរចាររវាងសហរដ្ឋអាមេរិក និងអ៊ីរ៉ង់លើកិច្ចព្រមព្រៀងនុយក្លេអ៊ែរ ទំនងជាអាចដកទណ្ឌកម្មលើការលក់ប្រេងនៅអ៊ីរ៉ង់ និងអាចបង្កើនការផ្គត់ផ្គង់ប្រេងនៅលើពិភពលោក



*ធុងស្តុកប្រេងឆៅត្រូវបានគេរកឃើញនៅក្នុងរូបថតពីលើអាកាសនៅមជ្ឈមណ្ឌលប្រេង Cushing ក្នុងទីក្រុង Cushing រដ្ឋ Oklahoma នៅសហរដ្ឋអាមេរិក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ ប្រភព៖ REUTERS/Drone Base*

សហរដ្ឋអាមេរិក និងអ៊ីរ៉ង់កំពុងតែបន្តកិច្ចចរចារ ដែលអាចស្តារកិច្ចព្រមព្រៀងនុយក្លេអ៊ែរ និងអាចដក

ទណ្ឌកម្មលើការលក់ប្រេងរបស់អ៊ីរ៉ង់ ដើម្បីធ្វើការបង្កើនការផ្គត់ផ្គង់ប្រេងនៅលើពិភពលោក។ កិច្ចពិភាក្សាស្តីពីការស្តារឡើងវិញនូវកិច្ចព្រមព្រៀងនុយក្លេអ៊ែររបស់អ៊ីរ៉ង់ឆ្នាំ២០១៥ ដែលកំពុងប្រព្រឹត្តទៅនៅទីក្រុងវីយ៉ែននឹងបន្តនៅថ្ងៃអង្គារ បន្ទាប់ពីបានពន្យាពេលអស់រយៈពេល ១០ថ្ងៃ។ សហរដ្ឋអាមេរិកបានបន្តស្តារឡើងវិញនូវការលើកលែងទណ្ឌកម្មមួយចំនួន ខណៈដែលអ៊ីរ៉ង់កំពុងទាមទារឱ្យមានការដកទណ្ឌកម្មទាំងស្រុង និងបានស្នើរសុំឱ្យមានការធានាពីសហរដ្ឋអាមេរិកថា នឹងមិនចាត់វិធានការដាក់ទណ្ឌកម្មបន្ថែមទៀតនោះទេ។

គួរកត់សំគាល់ថា តម្លៃប្រេងឆៅប្រភេទ Brent បានធ្លាក់ចុះ ២២សេន ឬ ០.២៤% ស្មើនឹង ៩២.៤៧ដុល្លារសហរដ្ឋអាមេរិក គិតត្រឹមម៉ោង ៧.១៦វិនាទីព្រឹកមិញ បន្ទាប់ពីតម្លៃប្រេងឆៅនេះឡើងដល់ ៩៤ដុល្លារសហរដ្ឋអាមេរិក កាលពីច័ន្ទ ដែលពុំធ្លាប់មាននៅក្នុងអំលុងពេល ៧ឆ្នាំកន្លងមកនេះ។ ចំណែកឯតម្លៃប្រេងឆៅរបស់សហរដ្ឋអាមេរិក West Texas Intermediate បានធ្លាក់ចុះ ១៤សេន ឬ ០.១៦% មកនៅត្រឹម ៩១.១៨ដុល្លារសហរដ្ឋអាមេរិកក្នុងមួយបារ៉ែល។ កិច្ចសន្យាប្រេងរបស់ប្រទេសទាំងពីរបានឈានដល់កម្រិតខ្ពស់មួយដែលពុំធ្លាប់មានក្នុងរយៈពេល ៧ឆ្នាំកន្លងមកនេះ ដោយសារការកើនឡើងនៃតម្រូវការរបស់ពិភពលោក និងភាពតានតឹងដែលកំពុងតែបន្តកើតមាននៅអឺរ៉ុបខាងកើត និងការរំខានចំពោះការផ្គត់ផ្គង់ដោយសារតែលក្ខខណ្ឌអាកាសធាតុនៅសហរដ្ឋអាមេរិកចាប់ផ្តើមចុះត្រជាក់។

អ្នកវិភាគរបស់ ANZ បាននិយាយកាលពីថ្ងៃអង្គារថា តម្លៃប្រេងឆៅនឹងបន្តធ្លាក់ចុះទាប ខណៈដែលប្រេងឆៅរបស់អ៊ីរ៉ង់កំពុងតែវាយលុកចូលទីផ្សារ និងបានរំពឹងថា វឌ្ឍនៈភាពនៃកិច្ចព្រមព្រៀងនេះនឹងអាចស្តារឡើងវិញនូវការដកទណ្ឌកម្មលើការផ្គត់ផ្គង់ប្រេងនៅលើពិភពលោក។ ទោះជាយ៉ាងណាអ្នកវិភាគយល់ឃើញថា តម្លៃប្រេងនឹងនៅតែបន្តកើនឡើង ដោយសារតែអារ៉ាប់ប៊ីសាអូឌីតតម្លើងថ្លៃប្រេង ខណៈពេលដែលរោងចក្រផលិតប្រេងនៅសហរដ្ឋអាមេរិកត្រូវបានបិតមិននឹកស្មានដល់ និងបើទោះបីជាប្រតិបត្តិការរោងចក្រចំរាញ់ប្រេងមួយចំនួននៅសហរដ្ឋអាមេរិកបានត្រលប់មករកភាពប្រក្រតីវិញក៏ដោយ។

លោក Edward Moya អ្នកវិភាគរបស់ OANA រំពឹងថា កិច្ចចរចារវាងសហរដ្ឋអាមេរិក និងអ៊ីរ៉ង់នឹងអាចជម្រុញឱ្យប្រាក់ចំណេញនៅក្នុងវិស័យប្រេងមានការកើនឡើង។ ដោយឡែកការធ្លាក់ចុះនៃតម្លៃប្រេងទំនងជានឹងមានរយៈពេលខ្លី ដោយសារការផ្គត់ផ្គង់ប្រេងនៅតែបន្តមានឱនភាព។ លោកបានរំពឹងទៀតថា តម្រូវការប្រេងឆៅនឹងមានភាពប្រសើរឡើងពេញមួយឆ្នាំនៅក្នុងឆ្នាំនេះ ខណៈដែលទីផ្សារប្រេងកំពុងតែរងសំពាធពីការផ្គត់ផ្គង់ប្រេងរបស់ប្រទេសទាំងពីរ និងកំពុងតែប្រឈមនឹងហានិភ័យភូមិសាស្ត្រនយោបាយ។

ចំណែកលោក Saudi Aramco បាននិយាយកាលពីថ្ងៃសៅរ៍ថា ខ្លួនបានដំឡើងថ្លៃប្រេងឆៅទាំងអស់ដែលបានលក់ទៅឱ្យប្រទេសអាស៊ីចាប់តាំងពីខែកុម្ភៈ រហូតដល់ខែមីនា ស្របតាមការព្យាករណ៍របស់ទីផ្សារ ដែលបានឆ្លុះបញ្ចាំងពីតម្រូវការដ៏រឹងមាំនៅអាស៊ី និងតម្រូវការប្រេងសាំង និងប្រេងយន្តហោះកាន់តែមានសន្ទុះកើនឡើង។ ដោយឡែកការស្ទង់មតិរបស់ Reuters កាលពីថ្ងៃច័ន្ទបានបង្ហាញថា ស្តុកប្រេងឆៅ និងប្រេងសាំងរបស់សហរដ្ឋអាមេរិកក៏ទំនងជាកើនឡើងផងដែរកាលពីសប្តាហ៍មុន ខណៈដែលបញ្ជីរសារពើភ័ណ្ឌចម្រាញ់

ប្រេងបង្ហាញថាបានធ្លាក់ចុះ។ ទោះយ៉ាងណា ស្តុកប្រេងឆៅត្រូវបានគេម្រមើលមើលថា នឹងកើនឡើងប្រហែល 700,000 បារ៉ែលរហូតដល់ថ្ងៃទី៤ ខែកុម្ភៈ។

*ដោយ វង្ស ច័ន្ទស្មើជាភា*

*ប្រភព៖ Channel News Asia ចេញផ្សាយ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២*

## ព្រឹត្តិការណ៍សេដ្ឋកិច្ចពិភពលោកធំៗទាំង ១០ ដែលបានកើតឡើងក្នុងឆ្នាំ២០២១




*ដោយ ខេមបុណ្ណមីស(ការដោះគាំងកប៉ាល់នៅក្នុងព្រែកជីកស៊ុយអេ)*

បើទោះបីជាក្នុងឆ្នាំ២០២១ ដំណើរការសេដ្ឋកិច្ចពិភពលោកហាក់មានសភាពយឺត តែវាជាដំណើរដែល សេដ្ឋកិច្ចបានរួចផុតពីវិបត្តិ ដែលបណ្តាលមកពីកូវីដ ១៩។ នៅឆ្នាំ២០២២នេះ សេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថា នឹងមានកំណើនយឺតជាងឆ្នាំ២០២១ ពោលគឺនឹងមានត្រឹមតែជាង៤%ប៉ុណ្ណោះ ខណៈឆ្នាំ ២០២១មានដល់ទៅ ៥,៥% នេះបើតាមការព្យាករពីធនាគារពិភពលោក។ *តើនៅឆ្នាំ២០២១ មានព្រឹត្តិការណ៍សេដ្ឋកិច្ចធំៗអ្វីខ្លះ បានកើតឡើង?*

**ទី១. ការងើបឡើងយ៉ាងឆាប់នៃសេដ្ឋកិច្ចពិភពលោក**

សេដ្ឋកិច្ចពិភពលោក បានងើបឡើងវិញយ៉ាងឆាប់រហ័ស នៅពេលចរន្តសេដ្ឋកិច្ចបានបើកឡើងវិញ និងដាក់ឱ្យប្រើប្រាស់កញ្ចប់សាច់ប្រាក់ជំរុញកំណើនសេដ្ឋកិច្ចនៅក្រោយវិបត្តិកូវីដ១៩។

**ទី២. វិបត្តិសង្វាក់ផ្គត់ផ្គង់សកល**

ការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ នៅតាមរោងចក្រនានាបានបណ្តាលឱ្យខ្វះខាតកម្លាំងពលកម្ម ការរំខានដល់ការផលិត ហើយធ្វើឱ្យមានអតុល្យភាពរវាងការផ្គត់ផ្គង់ទំនិញ និងតម្រូវការ។ ទន្ទឹមនេះ កង្វះកប៉ាល់ និងកុងតឺន័រនៅកំពង់ផែសមុទ្រសំខាន់ៗជុំវិញពិភពលោកក៏ជាបញ្ហាដល់ការដឹកជញ្ជូនតាមសមុទ្រដែរ ហើយថ្លៃដឹកជញ្ជូន ពីអាស៊ីទៅអឺរ៉ុបបានកើនឡើងប្រហែល១០ ដង និងពីប្រទេសចិនទៅតំបន់ភាគខាងលិចនៃសហរដ្ឋអាមេរិកកើនជិត៣ដង។

**ទី៣. ការប្តេជ្ញាចិត្តក្នុងការបញ្ឈប់ថាមពលប្រើធ្យូងថ្ម**

ក្នុងកិច្ចប្រជុំលើកទី ២៦ នៃសន្និសីទភាគីនៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ (COP26) ប្រទេសជាង ៤០ប្រទេស និងអង្គការនានាបានប្តេជ្ញាចិត្តក្នុងការបញ្ឈប់ការប្រើប្រាស់ថាមពលធ្យូងថ្ម និងឈប់គាំទ្រដល់ការសាងសង់រោងចក្រថាមពលធ្យូងថ្មថ្មីៗតទៅទៀត។

**ទី៤. កិច្ចព្រមព្រៀងសកលស្តីពីអត្រាពន្ធសាជីវកម្មអប្បបរមា**

រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលនៃប្រទេស(G20)បានអនុម័តកិច្ចព្រមព្រៀងជាសកលមួយដើម្បីកែលម្អប្រព័ន្ធពន្ធសាជីវកម្មពិភពលោក។ ចាប់ពីឆ្នាំ ២០២៣ អត្រាពន្ធសាជីវកម្មអប្បបរមាជាសកលចំនួន ១៥% នឹងត្រូវបានអនុវត្តចំពោះក្រុមហ៊ុនដែលមានប្រាក់ចំណូលពី ៨៧០ លានដុល្លារអាមេរិក ឬខ្ពស់ជាងនេះ ដែលវាត្រូវបានប៉ាន់ប្រមាណថា វិធានការនេះអាចនឹងប្រមូលប្រាក់ពន្ធបាន ១៥០ ពាន់លានដុល្លារក្នុងមួយឆ្នាំៗនៅក្នុងចំណូលពន្ធសកលលោក។

**ទី៥. ការវិលត្រឡប់មកវិញនូវគោលនយោបាយរូបិយវត្ថុធូររលុងរបស់ធនាគារកណ្តាល**

ធនាគារកណ្តាលឈានមុខគេរបស់ពិភពលោក បាន ចាប់ផ្តើមដកជាបណ្តើរៗនូវគោលនយោបាយរូបិយវត្ថុ ដែលធូររលុងខ្លាំង និងគោលនយោបាយអត្រាការប្រាក់ទាប បន្ទាប់ពីការអនុវត្តប្រហែលពីរឆ្នាំ ដើម្បីគាំទ្រដល់សេដ្ឋកិច្ចចំពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩។

**ទី៦. សកម្មភាពនៃការរួមបញ្ចូលគ្នា និងការទិញយកភាគហ៊ុនក្រុមហ៊ុននៅទូទាំងសកលលោក (M&A)**

សកម្មភាពនៃការច្របាច់បញ្ចូលគ្នា និងការទិញយកភាគហ៊ុនជាសកល (M&A) ឬហៅថា ការពង្រីកលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីទទួលបានចំណែកទីផ្សារក្នុងការបង្កើតតម្លៃភាគហ៊ុននោះ បានបំបែកកំណត់ត្រានៅក្នុងឆ្នាំ ២០២១ ពោលគិតត្រឹមខែធ្នូ ឆ្នាំមុន តម្លៃនៃការច្របាច់បញ្ចូលគ្នា និងការទិញរបស់ក្រុមហ៊ុននៅទូទាំងពិភពលោកបានកើនឡើងដល់ជាង ៥ទ្រីលានដុល្លារអាមេរិក។

**ទី៧. ការបង្ក្រាបលើសេដ្ឋកិច្ចរបស់ប្រទេសចិន**

ប្រទេសចិនបានចេញបទប្បញ្ញត្តិថ្មីៗជាច្រើនកាលពីឆ្នាំ ២០២១ ដើម្បីរឹតបន្តឹងការគ្រប់គ្រងក្នុងវិស័យបច្ចេកវិទ្យា អចលនទ្រព្យ និងការអប់រំ ដែលបង្កឱ្យមានសម្ពាធកាន់តែខ្លាំងលើក្រុមហ៊ុនឯកជន។ ជាក់ស្តែង ក្រុមហ៊ុនអចលនទ្រព្យយក្សរបស់ចិន Evergrande កំពុងស្ថិតនៅលើមាត់ជ្រោះមរណៈនៃការក្ស័យធន ដោយសារតែជំពាក់បំណុលជុំទិសរហូតដល់ប្រមាណ ៣០០ពាន់ដុល្លារ។ កន្លងមក រដ្ឋាភិបាលចិនបានដាក់កំហិតលើការផ្តល់ប្រាក់កម្ចីអចលនទ្រព្យដើម្បីទប់ស្កាត់ការឡើងថ្លៃផ្ទះ និងការខ្ចីប្រាក់ច្រើនពេកផងដែរ។

**ទី៨. ការកើនឡើងតម្លៃខ្ពស់បំផុតរបស់ Bitcoin**

Bitcoin ដែលជារូបិយប័ណ្ណគ្រីបតូធំជាងគេបំផុតរបស់ពិភពលោកបានឡើងដល់កំណត់ត្រាខ្ពស់ថ្មីមួយគឺជិត ៧ម៉ឺនដុល្លារកាលពីថ្ងៃទី ១០ ខែវិច្ឆិកា ហើយត្រូវបានគេព្យាករណ៍ថានឹងឡើងដល់ ១០ម៉ឺនដុល្លារក្នុងពេលឆាប់ៗនេះ។ ជុំវិញបញ្ហានេះ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) មានការព្រួយបារម្ភអំពីការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃរូបិយប័ណ្ណឌីជីថលដោយគ្មានបទប្បញ្ញត្តិគ្រប់គ្រងសមស្រប។

**ទី៩. ការជាប់គាំងកប៉ាល់ Ever Givenនៅក្នុងព្រែកជីកស៊ុយអេ**

កប៉ាល់ដឹកកុងតឺន័រខ្នាតយក្ស Ever Given បានជាប់គាំងនៅក្នុងព្រែកជីកស៊ុយអាកាលពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២១ ខណៈកប៉ាល់នេះផ្ទុកទំនិញមានតម្លៃប្រមាណ ១០ ពាន់លានដុល្លារក្នុងមួយថ្ងៃ។ ឧបទ្ទវហេតុនេះ បានធ្វើឱ្យមានការកកស្ទះចរាចរណ៍ និងប៉ះពាល់ដល់ផ្លូវដឹកជញ្ជូនរបស់ពិភពលោក ហើយវាក៏បានបង្ហាញពីភាពទន់ខ្សោយនៃឧស្សាហកម្មដឹកជញ្ជូនផងដែរ។

**ទី១០. ការប្រឈមមុខនឹងវិបត្តិថាមពល**

វិបត្តិផ្គត់ផ្គង់ថាមពលបានកើតឡើងនៅទូទាំងទ្វីបទាំងអស់។ ដោយតម្លៃឧស្ម័ននៅអឺរ៉ុបលក់ដុំបានកើនឡើងជាង ៨០០%, តម្លៃធ្យូងថ្មកើនឡើង ១១០% ហើយតម្លៃប្រេងឆៅបានកើនឡើងដល់លើសពី ៨០ ដុល្លារក្នុងមួយបារ៉ែល។ ការកើនឡើងនេះ ដោយសារតម្រូវការខ្លាំង បន្ទាប់ពីការបើកសេដ្ឋកិច្ចឡើងវិញ បូករួមទាំងការខ្វះខាតធ្យូងថ្ម និងឧស្ម័នយ៉ាងធ្ងន់ធ្ងរ។

ទាំង១០ចំនុចនេះ គឺជាព្រឹត្តិការណ៍សេដ្ឋកិច្ចសំខាន់ៗដែលបានកើតនាឆ្នាំ២០២១។ តើនៅឆ្នាំ២០២២នេះ តើនឹងមានព្រឹត្តិការណ៍សេដ្ឋកិច្ចសំខាន់ៗអ្វីកើតឡើងបន្តទៀត៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២។*

## ជប៉ុន ស្វែងរកការបញ្ជូនឧស្ម័នធម្មជាតិ ទៅកាន់អឺរ៉ុប បើរុស្ស៊ី បង្កភាពអាក់អន្លួល ក្នុងការផ្គត់ផ្គង់



*ដោយ dap-news*

សហរដ្ឋអាមេរិក បានព្រមានទីក្រុងមូស្គូពីការដាក់ទណ្ឌកម្ម ប្រសិនបើកងកម្លាំងរុស្ស៊ីឈ្លានពានអ៊ុយក្រែន ខណៈដែលកងទ័ពរុស្ស៊ីត្រូវបានដាក់ពង្រាយ នៅជិតព្រំដែនអ៊ុយក្រែន។

រដ្ឋបាលរបស់ប្រធានាធិបតីលោក ចូ បៃដិន បាននិយាយជាមួយមន្ត្រីនៃក្រុមហ៊ុននាំចូលឧស្ម័នធម្មជាតិធំៗ នៅអាស៊ី រួមទាំងប្រទេសជប៉ុន និងកូរ៉េខាងត្បូង អំពីការបង្វែរការផ្គត់ផ្គង់ឧស្ម័ន ទៅកាន់អឺរ៉ុប។ប្រទេស ជប៉ុនកំពុងថ្លឹងថ្លែងជម្រើសមួយដើម្បីផ្នែកខ្លះ នៃទុនបម្រុងឧស្ម័នធម្មជាតិរបស់ខ្លួន ទៅកាន់អឺរ៉ុប ក្នុងករណីដែលរុស្ស៊ីដាក់កម្រិតការផ្គត់ផ្គង់ឧស្ម័ន ជាការឆ្លើយតបទៅនឹងការដាក់ទណ្ឌកម្ម ដោយសារការលុកលុយរបស់រុស្ស៊ីលើអ៊ុយក្រែន។ ប្រទេសជប៉ុនទំនង ជាស្វែងរកការសម្របសម្រួល ជាមួយប្រទេសផ្សេងទៀតក្នុងការគាំទ្រអឺរ៉ុប ដែលពឹងផ្អែកយ៉ាងខ្លាំងលើការផ្គត់ផ្គង់ឧស្ម័នធម្មជាតិពីប្រទេសរុស្ស៊ី តាមរយៈបំពង់បង្ហូរប្រេង។ ប្រទេសជប៉ុន បាននិងកំពុងទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយសហរដ្ឋអាមេរិក និងបណ្តាប្រទេសអឺរ៉ុប ដោយបង្ហាញថាកិច្ចខិតខំប្រឹងប្រែង សម្របសម្រួលនឹងដំណើរការ ទៅដោយរលូន៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ dap-news ចេញផ្សាយថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២។*

## មេ Facebook ខាតបង់ប្រាក់ ២៩ ពាន់លានដុល្លារក្នុងមួយថ្ងៃ ខណៈមេAmazonរកបាន២០ពាន់លានដុល្លារ



លោក Mark Zuckerberg បានខាតបង់នូវទ្រព្យសម្បត្តិសុទ្ធ២៩ ពាន់លានដុល្លារកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន ដោយភាគហ៊ុនរបស់ក្រុមហ៊ុន Meta Platforms Inc (FB.O) ដែលជាក្រុមហ៊ុនមេរបស់ Facebook បានធ្លាក់ចុះខ្លាំងបំផុត។ ភាគហ៊ុនរបស់ Meta បានធ្លាក់ចុះ ២៦% ដោយបានបាត់បង់ថវិកាជាង ២០០ ពាន់លានដុល្លារ ដែលជាការបាត់បង់ដ៏ធំមិនធ្លាប់មានសម្រាប់ក្រុមហ៊ុនអាមេរិក។ ទន្ទឹមនឹងនេះ វាបានធ្វើអោយប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ ស្ថាបនិក និងជានាយកប្រតិបត្តិក្រុមហ៊ុន Metaផង។ លោក Zuckerberg មានភាគហ៊ុនប្រហែល ១២,៨% នៃក្រុមហ៊ុនមេរបស់ Facebookមួយនេះ។ ការធ្លាក់ចុះទ្រព្យសម្បត្តិមួយថ្ងៃរបស់ Zuckerberg គឺជាតួរលេខខាតបង់ដ៏ធំបំផុត ហើយបន្ទាប់ពីការខាតបង់នេះ នាយកប្រតិបត្តិក្រុមហ៊ុន Meta រូបនេះ បានធ្លាក់នៅលំដាប់ទី ១២ ក្នុងបញ្ជីមហាសេដ្ឋីពិភពលោកវិញ។

មហាសេដ្ឋីលោក Jeff Bezos ស្ថាបនិកក្រុមហ៊ុន Amazon នឹងកើនទ្រព្យសម្បត្តិ២០ ពាន់លានដុល្លារបន្ថែមទៀត។ លោក Bezos ជាស្ថាបនិក និងជាប្រធានក្រុមហ៊ុនលក់ទំនិញអេឡិចត្រូនិក Amazon មានភាគហ៊ុនប្រមាណ១០%នៃក្រុមហ៊ុនAmazon។

ទ្រព្យសម្បត្តិសុទ្ធរបស់លោក Bezos បានកើនឡើង ៥៧% មានដល់ទៅ ១៧៧ពាន់លានដុល្លារក្នុងឆ្នាំ ២០២១ក្នុងអំឡុងពេលរាតត្បាត មនុស្សពឹងផ្អែកខ្លាំងលើការទិញទំនិញតាមអ៊ីនធឺណិត ហើយលោកក៏ត្រូវបានគេស្គាល់ថា ជាមហាសេដ្ឋីមានជាងគេបំផុតទី៣របស់ពិភពលោកផងដែរ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២។*

## ចិនក្លាយជាប្រទេសនាំចូលអាហារពីជប៉ុនធំបំផុតជាលើកដំបូងក្នុងតម្លៃជិត២ពាន់លានដុល្លារ



*ដោយ ខេមបូណ្ឌមីស*

ប្រទេសចិន បានក្លាយជាប្រទេសនាំចូលផលិតផលម្ហូបអាហារពីជប៉ុនធំជាងគេបំផុតជាលើកដំបូងកាលពីឆ្នាំ ២០២១ ដោយបាននាំចូលក្នុងតម្លៃជិត២ពាន់លានដុល្លារ កើនឡើងជាង៣៥% ធៀបនឹងឆ្នាំ២០២០។ ក្នុងនោះមាន អាហារ ផលិតផលកសិកម្ម ឈើ ផលិតផលសមុទ្រ ស្រាជប៉ុន ស្រាវីស្គី និង ប្រភេទអាហារសម្រន់ ស្ថិតក្នុងចំណោមមុខម្ហូបពេញនិយមបំផុត សម្រាប់ការនាំចេញទៅកាន់ទីផ្សារចិន។ កំណើននេះ បានជួយឱ្យប្រទេសជប៉ុនសម្រេចបាននូវគោលដៅនាំចេញចំណីអាហារសរុបរបស់ខ្លួនដល់ទៅជាង ៨ ពាន់លានដុល្លារក្នុងមួយឆ្នាំផងដែរ។ ប្រទេសជប៉ុន ក៏កំពុងស្វែងរកការនាំចេញអាហារកាន់តែច្រើនបន្ថែមទៀត ដើម្បីស្តារឧស្សាហកម្មកសិកម្មឡើងវិញ ដែលកំពុងប្រឈមមុខនឹងការធ្លាក់ចុះទីផ្សារក្នុងស្រុកដោយសារចំនួនប្រជាជន ធ្លាក់ចុះ។ ការនាំចេញអាហារ និងផលិតកសិកម្មមានត្រឹមតែ ២% នៃផលិតកម្មក្នុងស្រុកសរុបរបស់ប្រទេសជប៉ុន។ បើធ្វើការប្រៀបធៀបការនាំចេញអាហារ និងផលិតកសិកម្មរបស់អង់គ្លេសមានដល់ទៅ ១៨% នៃផលិតកម្មក្នុងស្រុកសរុប ខណៈសហរដ្ឋអាមេរិកមាន ១២% ។

រហូតមកដល់បច្ចុប្បន្នមានប្រទេស និងដែនដីចំនួន ១៤ នៅតែរក្សាការរឹតបន្តឹងលើការនាំចេញរបស់ជប៉ុន ក្រោយជប៉ុនជួបនូវគ្រោះមហន្តរាយផ្ទុះរោងចក្រនុយក្លេអ៊ែរកាលពីឆ្នាំ ២០១១។ ជាមួយគ្នានេះ ប្រទេសចិនក៏បានហាមឃាត់ផលិតផលម្ហូបអាហារពីខេត្តចំនួន ៩ របស់ជប៉ុនផងដែរ។ កាលពីឆ្នាំមុន សហរដ្ឋអាមេរិក និងសិង្ហបុរីបានលុបចោលការរឹតបន្តឹងលើការនាំចូលរបស់លើផលិតផលចំណីអាហារជប៉ុន ខណៈហុងកុង និងសហភាពអឺរ៉ុបក៏បានបន្ធូរបន្ថយផងដែរ។ រាជរដ្ឋាភិបាលជប៉ុន នឹងធ្វើសកម្មភាព ដើម្បីជំរុញឱ្យប្រទេសនាំចូល លុបចោលការរឹតបន្តឹងទាំងនេះមកលើផលិតផលចំណីអាហារជប៉ុន ។

គោលដៅនៃការនាំចេញជប៉ុនត្រូវបានគេរំពឹងថា នឹងទទួលបានការជំរុញពីកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ដែលជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដំបូងគេដែលមានការចូលរួមពីប្រទេសជប៉ុន ចិន និងកូរ៉េខាងត្បូង ក្នុងចំណោមប្រទេសសមាជិកសរុប១៥ប្រទេស។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១៤ ខែកុម្ភៈ ឆ្នាំ២០២២

- តម្លៃទំនិញប្រើប្រាស់របស់ឥណ្ឌាបានធ្លាក់ចុះ 0.36% ធៀបនឹងខែមុនក្នុងខែធ្នូ ឆ្នាំ 2021 បន្ទាប់ពីការកើនឡើង 0.73%នៅក្នុងខែវិច្ឆិកា

- ឱនភាពពាណិជ្ជកម្មរបស់ឥណ្ឌាបានកើនឡើង ក្នុងខែមករា ឆ្នាំ 2022

ថ្ងៃអង្គារ ទី១៥ ខែកុម្ភៈ ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសឥណ្ឌូណេស៊ី បានរួមតូចយ៉ាងខ្លាំង ក្នុងខែធ្នូ ឆ្នាំ 2021
- អត្រានីកម្មភាពរបស់ចក្រភពអង់គ្លេសបាន ធ្លាក់ក្នុងរយៈពេលបីខែដល់ខែវិច្ឆិកា ឆ្នាំ 202

ថ្ងៃពុធ ទី១៦ ខែកុម្ភៈ ឆ្នាំ២០២២

- សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់នៅអាហ្វ្រិក ខាងត្បូងបានកើនឡើង 0.60%ក្នុងខែធ្នូ ឆ្នាំ 2021 ធៀបនឹងខែមុន
- តំបន់ចាយប្រាក់អឺរ៉ូ បានប្រកាសឱនភាព ពាណិជ្ជកម្មចំនួន 1.5 ពាន់លានអឺរ៉ូក្នុងខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

- ប្រទេសជប៉ុនបានចុះបញ្ជីឱនភាពពាណិជ្ជកម្ម ចំនួន 582.36 ពាន់លានយ៉េនក្នុងខែធ្នូ ឆ្នាំ 2021
- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអ៊ីតាលីបាន រួមតូចក្នុងខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃសុក្រ ទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

- អត្រានីកម្មភាព ប្រទេសបារាំងបានកើនឡើង ដល់ 8.1% នៅក្នុងត្រីមាសទី 3 ឆ្នាំ 2021
- ការងារនៅប្រទេសកាណាដា បានកើនឡើង 19.2 ពាន់នាក់ក្នុងខែធ្នូ ឆ្នាំ 2021 ដែលជា កម្រិតទាបបំផុតក្នុងរយៈពេល 4 ខែ៕